PPCBank

# របាយការណ៍ប្រចាំឆ្នាំ ២០២១

( គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ )

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ទស្សនវិស័យ

" យើងធ្វើឲ្យធនាគារមានលក្ខណៈងាយស្រួល។ "

# បេសកកម្ម

យើងនឹងបង្កើតទំនាក់ទំនងប្រកបដោយភាពស្និទ្ធស្នាល និងការជឿទុកចិត្ត ជូនដល់អតិថិជនដ៏មានតម្លៃរបស់ពួកយើង។ ពួកយើងក៏បានបង្កប់នូវគោលគំនិត "ភាពឆ្ពោះទៅមុខ" នៅក្នុងនិមិត្តសញ្ញារបស់ពួកយើង ដែលបង្ហាញពីការរីកចម្រើនប្រកបដោយនិរន្តភាពតាមរយៈការផ្លាស់ប្តូរ និងការបង្កើតថ្មី។

### ភាពឆ្ពោះទៅមុខ

ពួកយើងតែងតែទទួលយកនូវការផ្លាស់ប្តូរ ដែលជាភាពខ្លាំងក្នុងការប្រកួតប្រជែងរបស់ពួកយើង និងជាអ្នកត្រួសត្រាយខាងផ្នែកហិរញ្ញវត្ថុលក់រាយ ហើយពួកយើងមានគោលបំណងសម្រាប់ឧត្តមភាពតាមរយៈការបង្កើតថ្មី។

### ទំនុកចិត្ត

ទំនុកចិត្ត ត្រូវបានបង្កប់នូវអត្ថន័យដូចនឹងពាក្យថា "អ្នកថែរក្សាដើមឈើនៃភូមិមួយ" ដែលពួកយើងមានជំនឿថាភាពរីកចម្រើននឹងកើតមានតាមយៈ ទំនាក់ទំនងប្រកបដោយភាពស្និទ្ធស្នាល, ការជឿជាក់ និងភាពស្មោះត្រង់ ជាមួយនឹងអតិថិជនរបស់ពួកយើង។

### អតិថិជន

ក្នុងនាមជាក្រុមហិរញ្ញវត្ថុលក់រាយមួយ ពួកយើងនឹងធ្វើការលះបង់ ក្នុងការផ្តល់សេវាល្អបំផុតសម្រាប់អតិថិជនកម្រិតទាប-មធ្យម និងការលើកកម្ពស់សហគ្រាសខ្នាតតូច-មធ្យម។

### ចន្លោះ

ចន្លោះ ត្រូវបានយើងបញ្ចូលនៅក្នុងទស្សនៈរបស់យើង ដើម្បីធានាថាយើងបានប្តេជ្ញាចិត្តជាពិសេសជាមួយអតិថិជន តាមរយៈបណ្តាញចែកចាយប្រកបដោយភាពស្និទ្ធស្នាល និងភាពស្មោះត្រង់បានចាក់ឫសយ៉ាងខ្លាំង។

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤.០១៥.០៤១ | ៤.១៧៩.២៨៦ |
| បំណុលសរុប | ៣.៣០៦.៨១៧ | ៣.៥៤៩.៧៣៣ |
| មូលធនសរុប | ៧០៨.២២៤ | ៦២៩.៥៥៣ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ឆ្នាំ២០២១** | **ឆ្នាំ២០២០** |
| ចំណូលសរុប | ៣១២.១១១ | ២៩៧.១៥០ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ៩២.៩៧៣ | ៨៧.២៤៧ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ៧៤.០៤៨ | ៦៩.៨៧១ |
| លទ្ធផលម្អិតក្នុងការិយបរិច្ឆេទ | ៧៥.៩៤៣ | ៦៧.៩៥២ |
| **អនុបាតហិរញ្ញវត្ថុ(%)** | **ឆ្នាំ២០២១** | **ឆ្នាំ២០២០** |
| អនុបាតសាធនភាព❶ | ១៩,១៩ | ១៧,៣០ |
| អនុបាតបំណុលធៀបនឹងមូលធន | ៤៦៦,៩២ | ៥៦៣,៨៥ |
| អនុបាតសន្ទនីយភាព❶ | ១២៥,៤៦ | ១២៣,៥៩ |
| អនុបាតឥណទានមិនដំណើរការ | ១,៨២ | ១,០៤ |
| អនុបាតបញ្ញើធៀបនឹងឥណទាន | ៩៧,០៨ | ៨៦,៤៤ |
| **អនុបាតផលចំណេញ(%)** | **ឆ្នាំ២០២១** | **ឆ្នាំ២០២០** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA) | ១,៨៩ | ១,៦៣ |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE) | ១០,៧២ | ១០,៧៩ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ១៨៦,៨៣ | ១៧៤,១២ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | គ្មាន | គ្មាន |

សំគាល់ : ❶ អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយ ធនាគារជាតិ នៃកម្ពុជា។

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

សមាជិក



**KIM, Sung Chul**

សមាជិក



**PARK, Chong Tae**

អភិបាលឯករាជ្យ



**LEE, Myunsang**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការបង្ហាញពីលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងឆ្នាំ២០២១ ដោយអនុវត្តតាមតម្រូវការរបស់ និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ដូចដែលយើងទាំងអស់គ្នាបានជ្រាបរួចមកហើយអំពីការរីករាលតត្បាតនៃវីរុសកូរ៉ូណាថ្មី (COVID-19) ដែលបានរីករាលតត្បាតជាសកលយ៉ាងឆាប់រហ័ស ឆ្លងមនុស្សរាប់លាននាក់ និងធ្វើឲ្យសកម្មភាពសេដ្ឋកិច្ចនៅត្រឹង ក៏ដូចជាបណ្តាប្រទេសជាច្រើនបានដាក់កម្រិតយ៉ាងតឹងរឹងទៅលើការបំលាស់ទីដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសនេះ។ ដើម្បីទប់ស្កាត់ការរីករាលដាលវីរុសកូវីដ-១៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងក្នុងការស្វែងរកវ៉ាក់សាំងកូវីដ-១៩ ដើម្បីការពារប្រជាជនពីវីរុសដ៏កាចសាហាវមួយនេះ, កាត់បន្ថយការសម្រាកព្យាបាលនៅមន្ទីរពេទ្យ, ការជួយសង្គ្រោះជីវិតមនុស្ស និងការជួយស្តារសេដ្ឋកិច្ចប្រទេសជាតិឲ្យបានល្អប្រសើរឡើង។ ជាមួយនឹងការថយចុះជាលំដាប់នៃករណីកូវីដ-១៩ រាជរដ្ឋាភិបាលបានប្រកាសបើកប្រទេសឡើងវិញទាំងស្រុងលើគ្រប់វិស័យ ដើម្បីស្តារសេដ្ឋកិច្ចជាតិឡើងវិញ បន្ទាប់ពីរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយវីរុសរាតត្បាត កូវីដ-១៩ ក៏ដូចជាការប្រកាសបិទបញ្ចប់ ព្រឹត្តការណ៍វីរុសកូវីដ-១៩ ឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ផងដែរ។

ដើម្បីជួយពង្រឹងអនុបាតសាធនភាព ក៏ដូចជាទ្រនាប់ដើមទុនរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ឲ្យកាន់តែរឹងមាំ និងអនុលោមបានយ៉ាងពេញលេញទៅតាមតម្រូវការបទប្បញ្ញត្តិ ម្ចាស់ភាគហ៊ុន និងក្រុមប្រឹក្សាភិបាលនៃ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសម្រេចបញ្ចូលប្រាក់ចំណេញរក្សាទុកចំនួន ១០ លានដុល្លារអាមេរិក ចូលទៅក្នុងដើមទុនចុះបញ្ជី ដែលធ្វើឲ្យដើមទុនចុះបញ្ជីកើនពី ៩២ លានដុល្លារអាមេរិក ដល់ ១០២ លានដុល្លារអាមេរិក ស្មើនឹង ១០២.០០០ ភាគហ៊ុន ដែលក្នុងមួយភាគហ៊ុនមានតម្លៃ ១.០០០ ដុល្លារអាមេរិក (ស្មើនឹង ៤.០០០.០០០ លានរៀល) ដែលទទួលបាននូវការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ និងពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

លើសពីនេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ឲ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងប័ណ្ណថ្មី (New Card Management System) ដែលប្រព័ន្ធថ្មីនេះ នឹងជួយធ្វើឲ្យប្រសើរឡើងនូវដំណើរការ

ការងារផ្ទៃក្នុងរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ពីការធ្វើដោយដៃ មកជាការធ្វើដោយលក្ខណៈជាប្រព័ន្ធវិញ ហើយក៏ដូចជាការផ្ដល់នូវភាពងាយស្រួលសម្រាប់អតិថិជនផងដែរ។ ក្រៅពីនេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានទទួលការអនុញ្ញាតពី ធនាគារជាតិ នៃ កម្ពុជា ក្នុងការចូលរួមភាគកម្មវិនិយោគចំនួន ២០.០០០ ដុល្លារអាមេរិក នៅវិទ្យាស្ថាន ធនាគារ និងហិរញ្ញវត្ថុ (IBF)។

គិតត្រឹមចុងឆ្នាំ២០២១ កំណើននៃទ្រព្យសកម្មរបស់យើងគឺមានចំនួន ៩៨៦ លានដុល្លារអាមេរិក, ប្រាក់បញ្ញើមានចំនួន ៧៨៤ លានដុល្លារអាមេរិក, ឥណទានមានការកើន ៣,២% ពីចំនួន ៧២២ លានដុល្លារអាមេរិក ទៅ ៧៤៦ លានដុល្លារអាមេរិក, និងមូលធនមានការកើនឡើង ១១,៧% ពី ១៥៦ លានដុល្លារអាមេរិក ទៅ ១៧៤ លានដុល្លារអាមេរិក។ នេះគឺជាកំណើននៅក្នុងឆ្នាំ២០២០ ប្រៀបធៀបជាមួយឆ្នាំ២០២១ ដែលសមិទ្ធិផលរបស់ពួកយើងនេះ គឺជាអត្រាជោគជ័យក្នុងចំណោមដៃគូរប្រកួតប្រជែងហិរញ្ញវត្ថុជាច្រើននៅក្នុងទីផ្សារ។

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិទាំងអស់នៃធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ, បុគ្គលិករបស់យើងទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្ដេជ្ញាចិត្ត, អតិថិជនរបស់យើងទាំងអស់សម្រាប់ទំនុកចិត្តរបស់ពួកគេមកលើធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងនិយ័តករមូលបត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និងការគាំទ្រ។

ជាចុងក្រោយ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ជាមួយនឹងការបន្តការប្ដេជ្ញាចិត្ត និងការខិតខំប្រឹងប្រែង ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តរីកចម្រើន និងការអនុវត្តល្អបំផុតនៅឆ្នាំ២០២២ ជាមួយនឹងសមិទ្ធផលនៃគោលដៅផ្សេងបន្ថែមទៀត។

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

ហត្ថលេខា និងត្រា

YIM, Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្ដីថ្លែងរបស់នាយកប្រតិបត្តិ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ត្រូវបានចូលរួមជាចម្បងលើគ្រប់វិស័យនៃអាជីវកម្ម ធនាគារ និងការផ្ដល់សេវាហិរញ្ញវត្ថុដែលពាក់ព័ន្ធ។ សម្រាប់ឆ្នាំសារពើពន្ធ២០២១ របស់យើង ធនាគារទទួលបានកំណើនសមតុល្យដ៏ល្អប្រសើរ ទោះបីស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចពិបាកក៏ដោយ។

សេដ្ឋកិច្ចប្រទេសកម្ពុជា បានប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើនកាលពីឆ្នាំមុន ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។ ទោះបីជាយ៉ាងណា យើងរំពឹងថានឹងមានការងើបឡើងមកវិញខ្លះនៅដើមឆ្នាំ២០២២ ហើយយើងនៅតែមានសុទិដ្ឋិនិយមថា ប្រទេសកម្ពុជាអាចជម្នះពេលវេលាដ៏លំបាកនេះ និងបន្តការរីកចម្រើននាពេលអនាគតដ៏ខ្លីខាងមុខ។

ក្នុងឆ្នាំ២០២១ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អ៊ីស្ហួរិនស៍ ភីអិលស៊ី បានរៀបចំពិធីដាក់ឲ្យដំណើរការជាផ្លូវការ សម្រាប់ភាពជាដៃគូរ ដោយមានការទទួលស្គាល់ និងចូលរួមដោយតំណាងរបស់ ធនាគារជាតិ នៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏បានដាក់ឲ្យដំណើរការនូវផលិតផលឥណទាន អាជីវកម្មថ្មីមួយទៀតគឺ "ឥណទាន ៣០០" ដែលម្ចាស់អាជីវកម្មនឹងទទួលបាននូវការអនុម័តលើឯកសារកម្ចី ក្នុងរយៈពេល៣ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់នូវឯកសារតម្រូវទាំងអស់។ អតិថិជននឹងទទួលបានអត្រាការប្រាក់ថេរ ៩,៩៩% ក្នុងមួយឆ្នាំលក្ខខណ្ឌការប្រាក់នេះគឺសម្រាប់ ទាំងប្លង់រឹង និងប្លង់ទន់។ លើសពីនេះ ម្ចាស់សហគ្រាសធុនតូច និងមធ្យមអាចខ្ចីបានចាប់ពី ១ម៉ឺនដុល្លារអាមេរិក រហូតដល់ ៣០ម៉ឺនដុល្លារអាមេរិក ជាមួយរយៈពេលសងត្រលប់១២០ខែ ហើយកាន់តែពិសេសនោះគឺមានការអនុគ្រោះការសងប្រាក់ដើមក្នុងឆ្នាំទី១។ ម្យ៉ាងវិញទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏បានដាក់ឲ្យដំណើរការសេវាទូទាត់វិក័យបត្ររបស់ BanhJi នៅតាមបញ្ជររបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងតាម Mobile App ។ ភាពជាដៃគូរនេះ នឹងអនុញ្ញាតឲ្យអតិថិជន SME ទាំងអស់របស់ BanhJi អាចធ្វើការទូទាត់វិក័យបត្រតាមរយៈបណ្ដាញទូទាត់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក (តាមសាខា និងតាម Mobile App) ហើយក៏អនុញ្ញាតឲ្យធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ចូលដំណើរការទៅអតិថិជន SME របស់ BanhJi ផងដែរ ដែលនឹងធ្វើឲ្យតម្រូវការនៃគណនីរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មានការកើនឡើង។

បន្ថែមពីនេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបាននូវការអនុញ្ញាតពីអាជ្ញាធរ មានសមត្ថកិច្ច ដើម្បីធ្វើការអនុវត្តសកម្មភាពអាជីវកម្មធនាគារ និងការដាក់ឲ្យដំណើរការនូវផលិតផល និងសេវាថ្មីៗ និងមានស្រាប់របស់ខ្លួនដូចជា សេវាទូទាត់ឥណទានមកធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក តាមរយៈ ភ្នាក់ងារវីង, ការធ្វើឲ្យប្រសើរឡើងនូវសេវា Cardless Cash ដែលអនុញ្ញាតឲ្យអតិថិជនអាចធ្វើប្រតិបត្តិការដកប្រាក់ ជាប្រាក់រៀល និងដុល្លារអាមេរិក ពីគណនីរបស់ខ្លួន ហើយក៏អនុញ្ញាតឲ្យអតិថិជនប្តូរជាប្រភេទប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកពីការដកប្រាក់តាមតម្រូវការរបស់ខ្លួនផងដែរ, ការទទួលបាននូវការអនុញ្ញាតបន្ថែមពីអគ្គិសនីកម្ពុជា ក្នុងការពង្រីកអាជីវកម្មរបស់ខ្លួនសម្រាប់ការទូទាត់វិក័យបត្រថ្លៃប្រើប្រាស់ថាមពលអគ្គិសនីប្រចាំខែ ទៅអគ្គិសនីខេត្តចំនុះចំនួន ០៥ មានខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តកំពត ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ និងសេវាគ្រប់គ្រងបណ្ណ (Card Management Service) របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក អាចដំណើរការលើ Mobile App ដែលអនុញ្ញាតឲ្យអតិថិជនអាចឆែកមើលប័ណ្ណ (view card), ធ្វើឲ្យប័ណ្ណថ្មីដំណើរ (activate new card), ការមើលសមតុល្យ និងប្រតិបត្តិការប័ណ្ណ (card balance inquiry and transaction inquiry), បិទ/បើកដំណើរការប័ណ្ណ (block/unblock card), ការចេញ និងបន្តប័ណ្ណថ្មី (card re-issue and re-newal), ការផ្លាស់ប្តូរ និងកំណត់ PIN ឡើងវិញ (PIN change & reset PIN), ការគ្រប់គ្រងប័ណ្ណ (manage card limit), ការបើកប្រាក់ជាមុនភ្លាមៗ (សម្រាប់បណ្ណឥណទានបុគ្គល) instant cash advance (for credit card individual), ឆែកមើលព័ត៌មានលម្អិតពីការចេញវិក័យបត្រ (បណ្ណឥណទាន) view billing statement (Credit Card) ។ នៅថ្ងៃដដែលនេះ ការផ្ទេរប្រាក់តាមបាគងដោយផ្ទាល់ (Bakong Full Fund Transfer) របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏អាចដំណើរការលើ Mobile App បានផងដែរ ដែលសេវានេះអាចឲ្យអតិថិជនប្រើប្រាស់ Mobile App របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក អាចធ្វើការផ្ទេរសាច់ប្រាក់ទៅអ្នកទទួលបានភ្លាមៗ សម្រាប់ស្ថាប័នដែលជាសមាជិកបាគង តាមរយៈប្រព័ន្ធបាគងរបស់ធនាគារជាតិ។

ម្យ៉ាងវិញទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏បានបង្កើនផ្ទេរសាច់ប្រាក់ចូល (Inward Transfer) ពីធនាគារក្នុងស្រុកដែលជាសមាជិកបាគង ជាមួយនឹងចំនួនសាច់ប្រាក់មិនកំណត់ក្នុងមួយថ្ងៃ និងអាចផ្ទេររហូតដល់ ៥០.០០០ ដុល្លារអាមេរិក ឬ ២០០ លានរៀល ក្នុងមួយប្រតិបត្តិការ

និងបានចុះកិច្ចព្រមព្រៀងជាមួយ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) សម្រាប់សេវាប្រមូលការបង់ភាគទានប្រចាំខែជូនបេឡាជាតិសន្តិសុខសង្គម ចំពោះប្រតិបត្តិការបេឡាជាតិសន្តិសុខសង្គម។ តាមរយៈសេវានេះ នឹងផ្តល់ នូវភាពងាយស្រួលដល់អតិថិជន (ក្រុមហ៊ុន) របស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងអតិថិជនសក្តានុពលផ្សេងទៀត ក្នុងការបង់ភាគទានបេឡាជាតិសន្តិសុខសង្គម ទៅបេឡាជាតិសន្តិសុខសង្គម តាមរយៈធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។

សមិទ្ធផលផ្សេងៗទៀតដូចជា សេវាទទួលយកនូវប័ណ្ណ CSS សម្រាប់ធ្វើប្រតិបត្តិការនៅតាមបណ្តាម៉ាស៊ីន ATM ទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក, ការដាក់ឲ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាថ្មី SmartVista របស់ក្រុមហ៊ុន PBC ដើម្បីជម្រុញនូវយុទ្ធសាស្ត្រ ពង្រីកទីផ្សារ និងធ្វើឲ្យកាន់តែមានភាពងាយស្រួលដល់អតិថិជនរបស់ខ្លួននូវបទពិសោធនៃការប្រើប្រាស់សេវា ហើយក៏បានជ្រើសរើសប្រព័ន្ធបច្ចេកវិទ្យាមួយចំនួនពី SmartVista នេះផងដែរ។

នេះគឺជាការរីករាយបំផុតរបស់ខ្ញុំ ដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិក ក្រុមប្រឹក្សាភិបាល បុគ្គលិកគ្រប់លំដាប់ថ្នាក់សម្រាប់ការខិតខំប្រឹងប្រែង ការលះបង់ ភាពស្មោះត្រង់ និងការខិតខំធ្វើការងាររបស់ពួកគេ ជាពិសេសអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដូចជាធនាគារជាតិ នៃ កម្ពុជា (NBC), និយ័តករមូលបត្រកម្ពុជា (SERC), ...។ល។ ដែលបានគាំទ្រ និងផ្តល់ទិសដៅដល់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ពេញមួយឆ្នាំកន្លងមកនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

នាយកប្រតិបត្តិ

BAEK, Jongil

# មាតិកា


**ទស្សនវិស័យ** ........ 1

**បេសកកម្ម** ........ 1

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 2

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 3

**សមាសភាពក្រុមប្រឹក្សាភិបាល** ........ 4

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ........ 5

**សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ** ........ 7

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ........ 13

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ 13

ខ. លក្ខណៈនៃធុរកិច្ច ........ 14

គ. សម្ព័ន្ធភាពបុគ្គលចុះបញ្ជីលក់មូលបត្រ ........ 15

ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ 16

ង. ស្ថានភាពទីផ្សារ ........ 16

ច. ស្ថានភាពប្រកួតប្រជែង ........ 16

ឆ. ផែនការអនាគត ........ 17

ជ. កត្តាហានិភ័យ ........ 18

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ........ 19

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ........ 19

ខ. រចនាសម្ព័ន្ធចំណូល ........ 19

**ផ្នែកទី ៣ - ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** ........ 20

ក. អង្គការលេខ ........ 20

ខ. ក្រុមប្រឹក្សាភិបាល ........ 21

គ. បុគ្គលិកជាន់ខ្ពស់ ........ 21

**ផ្នែកទី ៤ - ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុននិករបស់បុគ្គលចុះបញ្ជីលក់មូលបត្រ** ........ 22

ក. ព័ត៌មានអំពីមូលបត្រ ........ 22

ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ ........ 22

គ. ភាគហ៊ុននិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ........ 23

ឃ. ភាគហ៊ុននិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ........ 23

ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣(បី)ឆ្នាំចុងក្រោយ ........ 23

**ផ្នែកទី ៥ - របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង** ........ 24

**ផ្នែកទី ៦ - របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយ សវនករឯករាជ្យ** ........ 28

**ផ្នែកទី ៧ - ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធនិងទំនាស់ផលប្រយោជន៍** ........ 28

ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ ........ 28

ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ ........ 28

គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម 28

ឃ.ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ ........ 29

ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលទំនាក់ទំនង

របស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ ..... 29

ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬ បុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល ..... 29

ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ 29

ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬ មិនមែនហិរញ្ញវត្ថុ ..... 29

**ផ្នែកទី ៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ..... 30

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... 30

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... 33

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... 35

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... 35

ង. ផលប៉ះពាល់នៃអតិផរណា ..... 35

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល ..... 36

**ហត្ថលេខាអភិបាលរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** ..... 37

ឧបសម្ព័ន្ធ៖ របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | Phnom Penh Commercial Bank Plc. |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/ ៩៩៩ ៥០០ |
| លេខទូរសារ | (+៨៥៥) ២៣ ៩៩៩ ៥៤០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ០៦៩/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០២ មេសា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Baek Jongil |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្តើមប្រតិបត្តិការធនាគារនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្តើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំ គឺ Jeonbuk Bank Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.), ក្រុមហ៊ុន Apro Financial Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co., Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co., Ltd.) ដែល មានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀត យើងក៏មិនភ្លេចនឹងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើង គាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមបំណាច់ខែធ្នូ ឆ្នាំ២០២១ ទ្រព្យសកម្មសរុបមានចំនួន ៩៨៦ លានដុល្លារអាមេរិក និងធ្វើការបម្រើអតិថិជនច្រើនជាង ១៥៨.០០០ នាក់ ជាមួយនឹងសាខាចំនួន ២៣ ទូទាំងប្រទេស និងម៉ាស៊ីន ATMs ចំនួន៦៨ (ម៉ាស៊ីន ATMs ផ្សេងៗទៀតកំពុងត្រូវបានពិចារណានៅទីតាំងសក្តានុពលផ្សេងៗទៀតក្នុងប្រទេសកម្ពុជា)។
បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តធ្វើការផ្តល់ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្តាញឌីជីថល ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ធនាគារ។ អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ live chat ក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ លើសពីនេះទៅទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតមជ្ឈមណ្ឌលសហគ្រាសធុនតូច-មធ្យម (SME Center) ជាលើកដំបូងរបស់ខ្លួន ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ សហគ្រាសធុនតូច-មធ្យម នឹងត្រូវទទួលបាននូវសេវាពិគ្រោះ

យោបល់អាជីវកម្មផងដែរ។ ពួកយើង ក៏បានពង្រីកនូវការិយាល័យបរទេស (Foreign Desk) មានដូចជា ការិយាល័យកូរ៉េ ជប៉ុន និងចិន ក៏ដូចជា ហ្គោលក្លឹប និងមជ្ឈមណ្ឌល SME ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និង បន្តធ្វើការអភិវឌ្ឍផលិតផល-សេវា របស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ.សម្ព័ន្ធភាពបុគ្គលចុះបញ្ជីលក់មូលបត្រ

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | % នៃការកាន់កាប់ភាគហ៊ុន | អាជីវកម្មចម្បង | កាលបរិច្ឆេទចុះបញ្ជីក្រុមហ៊ុន | ទីតាំងអាជីវកម្ម |
|---|---|---|---|---|---|---|
| ១ | ក្រុមហ៊ុន Jeonbuk Bank Co., Ltd. | ភាគទុនិក | ៥០% | សកម្មភាពធានារ៉ាប់រង និងហិរញ្ញវត្ថុ /សកម្មភាពអចលនទ្រព្យ និងការជួល | ០២ កក្កដា ១៩៩៣ | សាធារណៈរដ្ឋកូរ៉េ |
| ២ | ក្រុមហ៊ុន Apro Financial Co., Ltd. | ភាគទុនិក | ៤០% | សកម្មភាពធានារ៉ាប់រង និងហិរញ្ញវត្ថុ /ពាណិជ្ជកម្មលក់ដុំ និងរាយ | ០២ តុលា ១៩៩៩ | សាធារណៈរដ្ឋកូរ៉េ |
| ៣ | ក្រុមហ៊ុន JB Woori Capital Co., Ltd. | ភាគទុនិក | ១០% | សកម្មភាពធានារ៉ាប់រង និងហិរញ្ញវត្ថុ | ០៨ ធ្នូ ១៩៩៥ | សាធារណៈរដ្ឋកូរ៉េ |
| ៤ | ជេ&អេ (ខេមបូឌា) អ៊ិនវេសមិន ឯ.ក | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៤៩% | សកម្មភាពអចលនទ្រព្យដែលមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬ ជួល | ២៨ សីហា ២០១៤ | ប្រទេសកម្ពុជា |

## ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ




## ង. ស្ថានភាពទីផ្សារ

ដំណើរការនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅតែរឹងមាំក្នុងឆ្នាំ ២០២១ ទាក់ទងនឹងគុណភាពនៃឥណទាន និងប្រាក់បញ្ញើ បើទោះបីជាការធ្លាក់ចុះពីការរីករាលដាលនៃកូវីដ-១៩ ដែលបានរារាំងសកម្មភាពសេដ្ឋកិច្ចអស់រយៈពេលពីរឆ្នាំក៏ដោយ។ ជំងឺរាតត្បាតឥឡូវនេះត្រូវបានស្ថិតក្រោមការគ្រប់គ្រង ជាមួយនឹងភាពធន់ និងបទពិសោធន៍ដែលយើងទទួលបានក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាត។ ប្រាក់កម្ចីបានកើនឡើង ២១.២% ដែលមានចំនួន ៤៥.៧ ពាន់លានដុល្លារ កាលពីឆ្នាំមុន ខណៈដែលប្រាក់បញ្ញើរបស់អតិថិជនបានកើនឡើង ១៥.៤% ចំនួន៣៨.៥ ពាន់លានដុល្លារ។ កំណើននេះត្រូវបានជំរុញដោយការកើនឡើងនៃតម្រូវការកម្ចីក្នុងវិស័យពាណិជ្ជកម្ម លំនៅឋាន សំណង់ និងផលិតកម្ម ក្នុងចំណោមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជាបានផ្ដល់ប្រាក់កម្ចីសរុបចំនួន ៤៤.៩ ពាន់លានដុល្លារ ដែលគ្របដណ្ដប់លើវិស័យផលិតកម្ម សំណង់ ពាណិជ្ជកម្មលក់ដុំ និងរាយ កសិកម្ម ក្នុងចំណោមវិស័យផ្សេងៗទៀត។

## ច. ស្ថានភាពប្រកួតប្រជែង

វិស័យធនាគារមានស្ថិរភាពខ្លាំង ហើយបានចូលរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ការងើបឡើងវិញនៃសេដ្ឋកិច្ច និងភាពធន់។ សេដ្ឋកិច្ចត្រូវបានរំពឹងថានឹងបន្តងើបឡើងវិញ ចំពេលមានការរឹតបន្តឹងទាក់ទងនឹងកូវីដ-១៩។ កំណើន GDP ពិតប្រាកដត្រូវបានព្យាករណ៍ថានឹងឈានដល់ ៤.៥% នៅឆ្នាំ២០២២។ ប្រទេសកម្ពុជាមានធនាគារពាណិជ្ជប្រមាណចំនួន ៥៦

ធនាគារឯកទេសប្រមាណចំនួន ១១ និងស្ថាប័នមីក្រូហិរញ្ញវត្ថុប្រមាណចំនួន ៧៩ និងស្ថាប័នទទួលប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុប្រមាណ ៦ និងមានទីស្នាក់ការកណ្តាល និងសាខាសរុបចំនួន ២.៦០០ ព្រមទាំងម៉ាស៊ីន ATM ចំនួន៣.៥១២ នៅទូទាំងប្រទេស។ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក តែងតែត្រៀមខ្លួនរួចជាស្រេចក្នុងការបម្រើផលិតផល និងសេវាកម្មបន្ថែមទៀត ដើម្បីបំពេញតាមតម្រូវការនៃគោលបំណងរបស់អតិថិជន។ ក៏ដូចជាយើងប្តេជ្ញានាំយកនូវភាពច្នៃប្រឌិត ដើម្បីធានាបាននូវការធ្វើឱ្យធនាគារមានភាពងាយស្រួលជាងមុន។

## ឆ. ផែនការអនាគត

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរីកចម្រើនជាមួយនឹងការរំពឹងខ្ពស់បំផុតចាប់តាំងពីការបង្កើតរបស់យើងក្នុងឆ្នាំ២០០៨។ ជាមួយនឹងភាពរឹងមាំ ដែលយើងទទួលបាន និងការកើនឡើងជាបន្តបន្ទាប់នៃអតិថិជនរបស់យើងបានឈានដល់ការប្រើប្រាស់សេវា, ផែនការរបស់យើង គឺបន្តពង្រីកការពង្រីកខ្លួនឱ្យកាន់តែទូលំទូលាយដល់អតិថិជនរបស់យើងនៅទូទាំងប្រទេស។

ដើម្បីបង្កើតរឿងជោគជ័យមួយនៅអាស៊ីអាគ្នេយ៍ក្នុងឧស្សាហកម្មហិរញ្ញវត្ថុ ដោយធានានូវភាពប្រកួតប្រជែងដែលមានភាពខុសប្លែកគ្នា ដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធដែលអាចបត់បែនបាន និងមានលក្ខណៈជឿនលឿន ។

### ១. ផែនការរយៈពេលខ្លី (ផែនការអាជីវកម្មសម្រាប់រយៈពេល១ឆ្នាំ)

- ភ្ជាប់ជាមួយផែនការអាជីវកម្មរយៈពេលមធ្យម និងរយៈពេលវែង
- ប្រើទិន្នន័យជាមូលដ្ឋានសម្រាប់សមិទ្ធផលគោលដៅដោយធនាគារ / ការវាយតម្លៃ / ការផ្តល់រង្វាន់

### ២. ផែនការរយៈពេលមធ្យម និងរយៈពេលវែង (ផែនការអាជីវកម្មរយៈពេល៣ឆ្នាំ)

- កែតម្រូវ / បំពេញបន្ថែម ក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិយាកាសហិរញ្ញវត្ថុ
- ដឹកនាំទិសដៅគ្រប់គ្រងរយៈពេលមធ្យម

## ជ. កត្តាហានិភ័យ

### ១- ការវិភាគ

ហានិភ័យ ត្រូវបានគ្រប់គ្រងដោយផ្អែកលើកម្មវត្ថុរួមនៃការរក្សាភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ឬទ្រព្យសកម្ម និងជៀសវាងនូវសកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ។ ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ប្រតិបត្តិការអាជីវកម្ម គុណភាពឥណទាន និងការគ្រប់គ្រងសន្ទនីយភាព បានទទួលរងនូវការប៉ះពាល់ដោយផ្ទាល់ ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្ពស់ពីថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់។

### ២- ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់

ធនាគារ ភ្នំពេញពាណិជ្ជ ម.ក យល់យ៉ាងច្បាស់ពីកត្តាហានិភ័យទាំងនេះ និងបានត្រៀមខ្លួនរួចជាស្រេចដើម្បីភាពរីកចម្រើនក្នុងកាលៈទេសៈនេះ។ ធនាគារបានរក្សាយ៉ាងល្អនូវលំហូរសាច់ប្រាក់ បានកំណត់ប្រភពទុនច្រើនប្រភពផ្សេងគ្នា និងអាចគ្រប់គ្រងបាននូវឥណទានដែលមិនដំណើរការ។ ទន្ទឹមនឹងនោះ ប្រតិបត្តិការអាជីវកម្មនៅតែបន្តបាន ដោយមានការគាំទ្រពីផែនការយថាភាពអាជីវកម្មដែលបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ក៏ដូចជាដំណោះស្រាយធ្វើការងារពីផ្ទះ។

ធនាគារបន្តពង្រឹងមុខងារគ្រប់គ្រងហានិភ័យ វប្បធម៌គ្រប់គ្រងហានិភ័យ និងអនុវត្តន៍ដើម្បីធានាឲ្យបាននូវនិរន្តរភាពប្រតិបត្តិការអាជីវកម្ម។ ការពង្រឹងការគ្រប់គ្រងហានិភ័យទុកជាមុនជាមួយនឹងសកម្មភាពពាក់ព័ន្ធខាងក្រោមក៏ជាអាទិភាពចម្បងរបស់ធនាគារផងដែរ៖

- ពង្រឹងការធ្វើស្ត្រេសតេស្ត (Stress Testing) និងផែនការយថាភាព (សម្រាប់សន្ទនីយភាព និងឥណទាន) ជាមួយនឹងការកែប្រែ និង/ឬ បន្ថែមសូចនាករផ្តល់ដំណឹងមុន វិសាលភាពនៃស្ត្រេសតេស្ត សេណារីយ៉ូ និងវិធីសាស្ត្រ។
- ពង្រឹងការវាយតម្លៃហានិភ័យរួម ដោយរាប់បញ្ចូលទាំងហានិភ័យយុទ្ធសាស្ត្រ និងកេរ្តិ៍ឈ្មោះ។
- ការវិភាគម៉ត់ចត់លើការគ្រប់គ្រងហានិភ័យឥណទាន សន្ទនីយភាព និងសាធនភាព។

ធនាគារបន្តការត្រួតពិនិត្យ និងរាយការណ៍ជាប្រចាំនូវអនុបាតប្រុងប្រយ័ត្ន និងកម្រិតផ្ទៃក្នុង ដើម្បីធានាថាធនាគារទទួលបាននូវស្ថានភាពហិរញ្ញវត្ថុល្អ និងនិរន្តរភាពប្រតិបត្តិការធនាគារ។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៧.៣០៨ | ៦.៤៧៧ |
| ឥណទានដុលសរុប (លានរៀល) | ៣.០៣៧.៩៣១ | ២.៩២២.១៥៩ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៥៨.៥៦១ | ១៤៨.០២៥ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ៣.០២៩.៣៨៧ | ៣.២៦៣.៩៤៥ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៤៥ | ៤៧៤ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៦៨ | ៦៦ |
| ចំនួនម៉ាស៊ីនទូទាត់ | ២៣៨ | ២២៥ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ឆ្នាំ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | ចំនួន(លានរៀល) | ភាគរយ(%) | ចំនួន(លានរៀល) | ភាគរយ(%) |
| ១ | ចំណូលពីការប្រាក់ | ៣០១.៤៨១ | ៩៦,៥៩ | ២៨២.៦៨៨ | ៩៥,១៣ |
| ២ | ចំណូលកម្រៃ និង ជើងសារ | ៧.៨៣០ | ២,៥១ | ១៤.១៤២ | ៤,៧៦ |
| ៣ | ចំណូលផ្សេងៗ | ២.៨០០ | ០,៩០ | ៣១៩ | ០,១១ |
| | **ចំណូលសរុប** | **៣១២.១១១** | **១០០** | **២៩៧.១៥០** | **១០០** |

# ផ្នែកទី ៣ - ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក. អង្គការលេខ



## ខ. ក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | លោក Yim Yong Taick | ប្រធាន ក្រុមប្រឹក្សាភិបាល | ២១ កក្កដា ២០១៦ | ០៩ សីហា ២០២២ |
| ២ | លោក Kim Sung Chul | សមាជិក | ១៧ ឧសភា ២០២១ | ០៩ សីហា ២០២២ |
| ៣ | លោក Sim Sang Ton | សមាជិក | ២១ កក្កដា ២០១៦ | ០៩ សីហា ២០២២ |
| ៤ | លោក Park Chong Tae | សមាជិកឯករាជ្យ | ២១ កក្កដា ២០១៦ | ០៩ សីហា ២០២២ |
| ៥ | លោក Lee Myungsang | សមាជិកឯករាជ្យ | ១៧ កញ្ញា ២០១៩ | ០៩ សីហា ២០២២ |

ឈ្មោះលេខាធិការធនាគារ៖ លោក Park Naekyu

## គ. បុគ្គលិកជាន់ខ្ពស់

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | លោក Baek Jongil | ប្រុស | នាយកប្រតិបត្តិ |
| ២ | លោក ញ៉ក់ គឹមស្រួយ | ប្រុស | នាយកប្រតិបត្តិរងជាន់ខ្ពស់ |
| ៣ | លោក Park Naekyu | ប្រុស | នាយកជាន់ខ្ពស់ |
| ៤ | លោក ហេង ចន្ធា | ប្រុស | នាយកជាន់ខ្ពស់ |

សម្គាល់៖ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាឧបសម្ព័ន្ធ។

# ផ្នែកទី ៤ - ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុននិករបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. ព័ត៌មានអំពីមូលបត្រ

### ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មិនមានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិទេ។

### ២. ព័ត៌មានអំពីមូលបត្របំណុល

| ព័ត៌មាន | បរិយាយ | |
|---|---|---|
| ប្រភេទមូលបត្របំណុល | សញ្ញាបណ្ណសាជីវកម្ម | សញ្ញាបណ្ណសាជីវកម្ម |
| និមិត្តសញ្ញាមូលបត្របំណុល | PPCB23A | PPCB23B |
| កាលបរិច្ឆេទនៃការបោះផ្សាយ | ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ | ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ |
| តម្លៃសរុបនៃមូលបត្របំណុល | ៤០.០០០.០០០.០០០ រៀល | ៤០.០០០.០០០.០០០ រៀល |
| តម្លៃសរុបនៃមូលបត្របំណុលដែលកំពុងចរាចរ | មិនមាន | មិនមាន |
| ឥណប្រតិទាន | ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ | ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ |
| ការីភាគទូទាត់គូប៉ុង | ប្រចាំឆមាស | ប្រចាំឆមាស |
| អត្រាគូប៉ុង (%) | ៦,៥០% ក្នុងមួយឆ្នាំ | ៦,៥០% ក្នុងមួយឆ្នាំ |
| តម្លៃសរុបនៃការទូទាត់គូប៉ុង | មិនមាន | មិនមាន |
| ចំណាត់ថ្នាក់លទ្ធភាពសង(ប្រសិនមាន) | មិនមាន | មិនមាន |

## ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្របំណុល (PPCB23A) | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (លានរៀល) | អតិបរមា | - | - | - | - | - | - | - | - | - | - | - | - |
| | មធ្យម | - | - | - | - | - | - | - | - | - | - | - | - |
| | អប្បបរមា | - | - | - | - | - | - | - | - | - | - | - | - |
| បរិមាណជួញដូរ | អតិបរមា | - | - | - | - | - | - | - | - | - | - | - | - |
| | មធ្យម | - | - | - | - | - | - | - | - | - | - | - | - |
| | អប្បបរមា | - | - | - | - | - | - | - | - | - | - | - | - |

| មូលបត្របំណុល (PPCB23B) | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (លានរៀល) | អតិបរមា | - | - | - | - | - | - | - | - | - | - | - | - |
| | មធ្យម | - | - | - | - | - | - | - | - | - | - | - | - |
| | អប្បបរមា | - | - | - | - | - | - | - | - | - | - | - | - |
| បរិមាណជួញដូរ | អតិបរមា | - | - | - | - | - | - | - | - | - | - | - | - |
| | មធ្យម | - | - | - | - | - | - | - | - | - | - | - | - |
| | អប្បបរមា | - | - | - | - | - | - | - | - | - | - | - | - |

## គ. ភាគហ៊ុននិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

(ចាប់ពី ៣០%ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនភាគហ៊ុន | ភាគរយ |
|---|---|---|---|---|
| ១ | ក្រុមហ៊ុន Jeonbuk Bank Co., Ltd. | កូរ៉េ (ខាងត្បូង) | ៥១.០០០ | ៥០% |
| ២ | ក្រុមហ៊ុន Apro Financial Co., Ltd. | កូរ៉េ (ខាងត្បូង) | ៤០.៨០០ | ៤០% |
| សរុប | | | សរុប | ៩១.៨០០ |

## ឃ. ភាគហ៊ុននិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

(ចាប់ពី ៥% ដល់តិចជាង ៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនភាគហ៊ុន | ភាគរយ |
|---|---|---|---|---|
| ១ | ក្រុមហ៊ុន JB Woori Capital Co., Ltd. | កូរ៉េ (ខាងត្បូង) | ១០.២០០ | ១០% |
| សរុប | | | សរុប | ១០.២០០ |

## ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣(បី)ឆ្នាំចុងក្រោយ

(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ)

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មិនមានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិទេ។

# ផ្នែកទី ៥ -

# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

## សេចក្ដីផ្ដើម

មុខងារសវនកម្មផ្ទៃក្នុង ណែនាំដោយគោលនយោបាយសវនកម្ម និងប្រធានសវនកម្មផ្ទៃក្នុង ដែលរាយការណ៍ជាគោលការណ៍ទៅគណៈកម្មការសវនកម្ម និងជារដ្ឋបាលទៅនាយកប្រតិបត្តិ។ មុខងារនេះ គឺមានភាពឯករាជ្យទៅលើរាល់សម្មភាព ឬប្រតិបត្តិការនៃផ្នែកប្រតិបត្តិដទៃផ្សេងទៀត។ សវនកម្មផ្ទៃក្នុងបន្តអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃ ដើម្បីធានាថាប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុង បន្តប្រតិបត្តិយ៉ាងមានប្រសិទ្ធិភាព ដើម្បីកាត់បន្ថយហានិភ័យដែលធនាគារប្រឈម។ ហានិភ័យសំខាន់ៗ និងការមិនប្រតិបត្តិតាមនានា ដែលប៉ះពាល់ដល់ប្រតិបត្តិការរបស់ធនាគារ គឺត្រូវបានគូសបញ្ជាក់ ហើយអនុសាសន៍កែលម្អដែលសមស្របត្រូវបានផ្ដល់ជូន ដើម្បីពង្រឹងប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច។ បេសកកម្មរបស់សវនកម្មផ្ទៃក្នុង គឺអនុវត្តការត្រួតពិនិត្យ និងការស៊ើបអង្កេតសវនកម្មយ៉ាងហ្មត់ចត់ និងជាប្រចាំ ក្នុងគោលបំណងផ្ដល់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង នូវឯកសារចងក្រងនៃការវាយតម្លៃ និងអនុសាសន៍ទៅលើះ

- ប្រសិទ្ធភាព នៃនីតិវិធី រួមទាំងដំណើរការ នៃការកំណត់ ការវាស់វែង ការតាមដាន ការគ្រប់គ្រង និងការកម្រិតហានិភ័យ។
- ប្រសិទ្ធភាព នៃនីតិវិធី និងដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុង ព្រមទាំងដំណើរការដ៏សមស្រប ដែលត្រូវបានបង្កើតឡើង ដើម្បីបញ្ចៀសពីស្ថានភាពទំនាស់ផលប្រយោជន៍ ឬនៅពេលចាំបាច់ត្រូវដោះស្រាយស្ថានភាពទាំងនោះប្រកបដោយការប្រុងប្រយ័ត្ន រួមទាំង
- ភាពគ្រប់គ្រាន់ និងប្រសិទ្ធភាព នៃការត្រួតពិនិត្យការប្រតិបត្តិតាម និងការប្រកាន់ខ្ជាប់យ៉ាងពេញលេញ នូវគោលនយោបាយដែលបានដាក់ចេញដោយក្រុមប្រឹក្សាភិបាល។

## វត្ថុបំណង និងវិសាលភាព នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងត្រូវបង្កើតវត្ថុបំណងដែលរួមបញ្ចូល (CARES) មួយឬច្រើនដូចខាងក្រោម៖

- ការប្រតិបត្តិតាម បទប្បញ្ញត្តិ គោលនយោបាយ នីតិវិធី គោលការណ៍ណែនាំ និងកិច្ចព្រមព្រៀងផ្សេងៗ។
- សមិទ្ធិផល នៃគោលដៅយុទ្ធសាស្ត្រនានា របស់ស្ថាប័ន
- ភាពជាក់លាក់ និងភាពត្រឹមត្រូវ នៃព័ត៌មានហិរញ្ញវត្ថុ និងប្រតិបត្តិការ
- ប្រសិទ្ធភាព និងប្រសិទ្ធផល នៃប្រតិបត្តិការ និងកម្មវិធីផ្សេងៗ ព្រមទាំង
- ការការពារនៃទ្រព្យសកម្ម

## គោលនយោបាយ និងគោលការណ៍ណែនាំផ្ទៃក្នុង ដែលដាក់ចេញដោយ នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ដើម្បីអនុលោមតាមវត្ថុបំណងទូទៅ នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គោលនយោបាយ និងគោលការណ៍ណែនាំផ្ទៃក្នុងមួយចំនួន ដែលស្ថិតក្រោម នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតឡើងដូចខាងក្រោម៖

- គោលនយោបាយគណៈកម្មការសវនកម្ម (បង្កើតថ្មី)
- គោលនយោបាយសវនកម្មផ្ទៃក្នុង (ធ្វើវិសោធកម្មលើកទី១)
- គោលនយោបាយប្រធានសវនកម្មផ្ទៃក្នុង (បង្កើតថ្មី)
- គោលការណ៍ណែនាំពីការធ្វើសវនកម្មផ្ទាល់ខ្លួនរបស់សាខា (បង្កើតថ្មី)
- នីតិវិធីនៃសវនកម្មផ្ទៃក្នុង (ធ្វើវិសោធកម្មលើកទី២)
- នីតិវិធីនៃការវាយតម្លៃហានិភ័យ (បង្កើតថ្មី)

## ការសង្ខេបនៃសកម្មភាពរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងឆ្នាំ២០២១

ផែនការប្រចាំឆ្នាំរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងឆ្នាំ២០២១ ត្រូវបានអនុម័ត ដោយគណៈកម្មការសវនកម្ម។ របាយការណ៍ត្រួតពិនិត្យនៃការធ្វើសវនកម្មលើនាយកដ្ឋាន និងសាខានានា ត្រូវបានរាយការណ៍ជូនគណៈកម្មការសវនកម្ម ជារៀងរាល់ត្រីមាស ។

ក្នុងឆ្នាំ២០២១ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះធ្វើសវនកម្មចំនួន ១៧សាខា និង ៧ នាយកដ្ឋាន ។ លើសពីនេះទៅទៀត នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានធ្វើការចុះត្រួតពិនិត្យសាច់ប្រាក់ និងឯកសារសំខាន់ៗដោយមិនផ្តល់ដំណឹងទុកជាមុន សម្រាប់សាខាទាំងអស់ស្ថិតក្នុងតំបន់រាជធានីភ្នំពេញ។

| ល.រ | ខែ | សាខា | នាយកដ្ឋាន |
|---|---|---|---|
| ១ | មករា ២០២១ | ២ | ១ |
| ២ | កុម្ភៈ ២០២១ | ២ | |
| ៣ | មីនា ២០២១ | ២ | |
| ៤ | មេសា ២០២១ | | |
| ៥ | ឧសភា ២០២១ | ២ | |
| ៦ | មិថុនា ២០២១ | ២ | |
| ៧ | កក្កដា ២០២១ | | ១ |
| ៨ | សីហា ២០២១ | | ១ |
| ៩ | កញ្ញា ២០២១ | ២ | ១ |
| ១០ | តុលា ២០២១ | ១ | |
| ១១ | វិច្ឆកា ២០២១ | ២ | ២ |
| ១២ | ធ្នូ ២០២១ | ២ | ១ |
| **សរុប** | | **១៧** | **៧** |

របាយការណ៍របស់សវនកម្មផ្ទៃក្នុង ត្រូវបានដាក់ចេញ ដោយរួមបញ្ចូលនូវសមាសធាតុដូចខាងក្រោម៖

- លក្ខណៈវិនិច្ឆ័យ
- លក្ខខណ្ឌ
- ដើមហេតុ
- ហានិភ័យ និងផលប៉ះពាល់
- អនុសាសន៍របស់សវនករ
- ផែនការសកម្មភាព និងកាលបរិច្ឆេទនៃការកែតម្រូវលើបញ្ហាដែលផ្តល់ដោយសវនដ្ឋាន
- ចំណាត់ថ្នាក់លើការរកឃើញ
- ស្ថានភាពនៃការរកឃើញ

## ការសន្និដ្ឋាន

លទ្ធផលនៃការចុះត្រួតពិនិត្យ ត្រូវបានដាក់ចេញទៅនាយកដ្ឋាន និងសាខាដែលទទួលបន្ទុក រួមទាំង មន្ត្រីប្រតិបត្តិជាន់ខ្ពស់ទទួលបន្ទុក និងនាយកប្រតិបត្តិ។ រាល់អនុសាសន៍ ត្រូវបានទទួលយកដោយគណៈគ្រប់គ្រង ហើយផែនការសកម្មភាពកែតម្រូវទាំងអស់ ត្រូវបានអនុវត្តដោយសាខា និងនាយកដ្ឋាននានាបានទាន់ពេលវេលា។

ជាទូទៅ ការគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច គឺត្រូវបានរៀបចំឡើងគ្រប់គ្រាន់ និងអនុវត្តយ៉ាងមានប្រសិទ្ធិភាព។

បានអាន និងឯកភាព

.........ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២

ហត្ថលេខា

LEE Myungsang

ប្រធានគណៈកម្មាធិការសវនកម្ម

.........ថ្ងៃទី១១ខែមីនា ឆ្នាំ២០២២

ហត្ថលេខា

Na Byeongtae

ប្រធានសវនករផ្ទៃក្នុង

# ផ្នែកទី ៦ - របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមមើលឧបសម្ព័ន្ធរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ។

# ផ្នែកទី ៧ - ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញពីព័ត៌មានប្រត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធនៅក្នុងរយៈពេល ២(ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះ ដូចខាងក្រោម៖

**ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ**

មិនមាន

**ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់**

សូមមើលឧបសម្ព័ន្ធរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យសម្រាប់កំណត់សំគាល់ពាក់ព័ន្ធនឹង សម្ព័ន្ធញាតិ។

**គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម**

មិនមាន

**ឃ.ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

មិនមាន

**ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ**

មិនមាន

**ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល**

មិនមាន

**ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ**

មិនមាន

**ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

សូមមើលឧបសម្ព័ន្ធរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យសម្រាប់កំណត់សំគាល់ពាក់ព័ន្ធនឹង សម្ព័ន្ធញាតិ។

# ផ្នែកទី ៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក (PPCBank) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co., Ltd គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ឆ្នាំ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៣០១.៤៨១ | ៩៦,៥៩ | ២៨២.៦៨៨ | ៩៥,១៣ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៧.៨៣០ | ២,៥១ | ១៤.១៤២ | ៤,៧៦ |
| ៣ | ចំណូលផ្សេងៗ | ២.៨០០ | ០,៩០ | ៣១៩ | ០,១១ |
| ចំណូលសរុប | | ៣១២.១១១ | ១០០ | ២៩៧.១៥០ | ១០០ |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលដ៏ធំមកពីការប្រាក់ដែលមាន ៩៧% នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០២១។

### ៣. ការវិភាគគម្លាតចំណេញដុល

របាយការណ៍លទ្ធផលរួមរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ត្រូវបានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុលទេ ទម្រង់របាយការណ៍នេះបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុប ដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកបង្ហាញនិងពិភាក្សានៅក្នុងចំណុចបន្ទាប់លើការវិភាគចំណេញ(ខាត)មុនបង់ពន្ធដូចខាងក្រោម។

### ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៍ចំនេញខាត | ឆ្នាំ២០២១ (លានរៀល) | ឆ្នាំ២០២០ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៣០១.៤៨១ | ២៨២.៦៨៨ | ១៨.៧៩៣ | ៦,៦៥ |
| ចំណាយលើការប្រាក់ | (១០៩.២៦២) | (១១៥.១១៧) | ៥.៨៥៥ | (៥,០៩) |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **១៩២.២២០** | **១៦៧.៥៧២** | **២៤.៦៤៨** | **១៤,៧១** |
| ចំណូលកម្រៃ និងជើងសារ | ៧.៨៣០ | ១៤.១៤២ | (៦.៣១៣) | (៤៤,៦៤) |
| ចំណាយកម្រៃ និងជើងសារ | (៤.៣៦២) | (៤.៣៩២) | ៣០ | (០,៦៨) |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | **៣.៤៦៨** | **៩.៧៥១** | **(៦.២៨៣)** | **(៦៤,៤៤)** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២.៨០០ | ៣១៩ | ២.៤៨១ | ៧៧៧,៥៥ |
| ចំណាយបុគ្គលិក | (៣៣.២៦១) | (៣១.៦៣២) | (១.៦២៩) | ៥,១៥ |
| ចំណាយប្រតិបត្តិការ | (៣១.១៨៣) | (២៨.៧៨៦) | (២.៣៩៦) | ៨,៣២ |
| ចំណាយរំលស់ | (៣១.៥៧៣) | (២៨.១០៧) | (៣.៤៦៥) | ១២,៣៣ |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **១០២.៤៧១** | **៨៩.១១៦** | **១៣.៣៥៥** | **១៤,៩៩** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (៩.៤៩៨) | (១.៨៦៩) | (៧.៦២៩) | ៤០៨,១៤ |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៩២.៩៧៣** | **៨៧.២៤៧** | **៥.៧២៦** | **៦,៥៦** |

ក្នុងឆ្នាំ២០២១ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ៩២.៩៧៣លានរៀល (៦,៦%កើនឡើងប្រៀបធៀបទៅនឹងឆ្នាំ២០២០)។ ការកើនឡើងនៃប្រាក់ចំណេញភាគច្រើនគឺមកពីការកើនឡើង

នៃចំណូលការប្រាក់សុទ្ធដូចជា ការប្រាក់បានមកពីកម្ចីរបស់អតិថិជន និងការប្រាក់បានមកពីការដាក់ប្រាក់បញ្ញើនៅធនាគារផ្សេង។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ឆ្នាំ២០២១ (លានរៀល) | ឆ្នាំ២០២០ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៩២.៩៧៣ | ៨៧.២៤៧ | ៥.៧២៦ | ៦,៥៦ |
| ចំណាយពន្ធលើប្រាក់ចំណូល | (១៨.៩២៦) | (១៧.៣៧៦) | (១.៥៥០) | ៨,៩២ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **៧៤.០៤៨** | **៦៩.៨៧១** | **៤.១៧៧** | **៥,៩៨** |

ក្នុងឆ្នាំ២០២១ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ៧៤.០៤៨លានរៀល ដែលបានកើនឡើង ៦% ប្រៀបធៀបទៅនឹងឆ្នាំ២០២០ ដែលបណ្ដាលមកពីការកើនឡើងនៃចំណូលការប្រាក់សុទ្ធដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ឆ្នាំ២០២១ (លានរៀល) | ឆ្នាំ២០២០ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ៧៤.០៤៨ | ៦៩.៨៧១ | ៤.១៧៧ | ៥,៩៨ |
| ការខាតលម្អិតផ្សេងៗ | ១.៨៩៥ | (១.៩១៩) | ៣.៨១៤ | (១៩៨,៧១) |
| **ប្រាក់ចំណេញលម្អិតសរុប** | **៧៥.៩៤៣** | **៦៧.៩៥២** | **៧.៩៩១** | **១១,៧៦** |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ក្នុងឆ្នាំ ២០២១ ការទទួលរងផលប៉ះពាល់ពីការរាតត្បាតនៃវីរុសឆ្លង កូវីដ-១៩ បានបន្តរាលដាលចូលដល់សហគមន៍ ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ច និងវិស័យសំខាន់ៗក្នុងប្រទេសកម្ពុជា ។ ដូច្នេះដើម្បីទប់ស្កាត់ និងស្តារសេដ្ឋកិច្ចឡើងវិញពីផលប៉ះពាល់ដែលបង្កឱ្យមានការរំខានដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជាបានបន្តដាក់ចេញនូវកម្មវិធីចាក់វ៉ាក់សាំងការពារវីរុស កូវីដ-១៩ សម្រាប់ដូសជម្រុញជាបន្តបន្ទាប់ ដើម្បីធានាឲ្យបាននូវភាពស៊ាំក្នុងសហគមន៍ពីការឆ្លង ដែលបានជួយឲ្យប្រទេសកម្ពុជារួចផុតពីការរីករាលដាលនៃវីរុស កូវីដ-១៩

យ៉ាងឆាប់រហ័ស។ ដូចនេះ គណៈគ្រប់គ្រងយល់ឃើញថា សកម្មភាពអាជីវកម្មរបស់ក្រុម និងធនាគារ នឹងកាន់តែមានភាពល្អប្រសើរឡើងជាងមុន ទាំងទំហំនៃប្រតិបត្តិការ និងកម្រិតនៃប្រាក់ចំណេញ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ការបន្តទទួលបានមូលនិធិថ្មីៗជាមួយនឹងថ្លៃដើមទាប និងកំណើននៃផលិតផលកម្ចី SME នៅតែជាកត្តាសំខាន់បំផុតនៃប្រាក់ចំណេញរបស់ធនាគារ។ ដើម្បីសម្រេចបាននូវគោលដៅនេះ ធនាគារបានបង្កើតនូវផលិតផលកម្ចី SME ថ្មីៗបន្ថែមទៀតដូចជា៖ "ឥណទាន ៣០០", "ឥណទានកក់ក្តៅ" ដែលបានផ្តល់លក្ខខណ្ឌល្អប្រសើរ និងការអនុម័តលឿនជាងមុនតាមតម្រូវការរបស់អតិថិជន ដើម្បីផ្តល់អត្ថប្រយោជន៍កាន់តែច្រើន និងកាត់បន្ថយពេលវេលារង់ចាំសម្រាប់អតិថិជន ក្នុងស្ថានភាពបរិយាកាសនៃការរីករាលដាលនៃមេរោគកូវីដ-១៩។

ជាងនេះទៅទៀត ដើម្បីបម្រើសេវាអតិថិជនឱ្យកាន់តែប្រសើរ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធឌីជីថលរបស់ធនាគារ ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងអំឡុងពេលនៃការរីករាលដាលនៃមេរោគកូវីដ-១៩ ធនាគារបានបន្តវិនិយោគឥតឈប់ឈរ លើការលើកកម្ពស់សេវាធនាគារឌីជីថលរបស់ខ្លួនក្នុងអំឡុងឆ្នាំ២០២១ដូចជា៖

- ធ្វើឱ្យប្រសើរឡើងនូវសេវាកម្ម ដកសាច់ប្រាក់ដោយមិនប្រើប្រាស់កាត (Cardless Cash Service) របស់ខ្លួនដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការបានទាំងគណនីដកប្រាក់រៀល និងដុល្លារអាមេរិក ព្រមទាំងអាចអនុញ្ញាតឱ្យអតិថិជនធ្វើការប្តូររូបិយប័ណ្ណពីគណនីដកប្រាក់ផងដែរ។
- សេវាគ្រប់គ្រងបណ្ណ (Card Management Service) របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ត្រូវបានដាក់ឲ្យដំណើរការលើ Mobile App ដែលអនុញ្ញាតឲ្យអតិថិជនអាច ឆែកមើលប័ណ្ណ (view card) ធ្វើឲ្យប័ណ្ណថ្មីដំណើរ (activate new card) ការមើលសមតុល្យ និងប្រតិបត្តិការប័ណ្ណ (card balance inquiry and transaction inquiry) បិទ/បើកដំណើរការប័ណ្ណ (block/unblock card) ការចេញ និងបន្តប័ណ្ណថ្មី (card re-issue and re-newal) ការផ្លាស់ប្តូរ និងកំណត់ PIN ឡើងវិញ (PIN change & reset PIN) ការគ្រប់គ្រងប័ណ្ណ (manage card limit) ការបើកប្រាក់ជាមុនភ្លាមៗ (សម្រាប់បណ្ណឥណទានបុគ្គល) instant cash advance (for credit

card individual) ដែលមើលព័ត៌មានលម្អិតពីការចេញវិក័យបត្រ (បណ្ណឥណទាន) view billing statement (Credit Card) ។

- សេវាទូទាត់វិក្កយបត្ររបស់អគ្គិសនីកម្ពុជា (EDC) តាមរយៈបញ្ជរ និង Mobile App របស់ធនាគារ ត្រូវបានដាក់ឲ្យតំណើរការ ក្នុងការទូទាត់វិក្កយបត្រ EDC ។
- ធនាគារ PPCBank បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោយជោគជ័យជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ភាពជាដៃគូលើ ការប្រមូលប្រាក់ថៃទាំសុខភាពប្រចាំខែ។
- បានដាក់ឱ្យដំណើរការជាផ្លូវការ នូវសេវាផ្ទេរប្រាក់ពេញលេញដែលកាត់ចេញ និងទទួលសម្រាប់គណនីរបស់អតិថិជនដែលមាននៅធនាគារ សម្រាប់ប្រព័ន្ធបាគងនៅបញ្ជរ បន្ថែមទៅលើសេវាដែលបានដាក់ឱ្យដំណើរការស្រាប់លើសេវា ធនាគារចល័ត (Mobile Banking) និងសេវាធនាគារតាមអ៊ីនធឺណែត។
- CSS ATM Acquiring Service ដែលត្រូវបានប្រកាសជាផ្លូវការ និងអនុវត្តនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១។ CSS ត្រូវបានរចនាឡើងដើម្បីផ្តល់នូវទំនាក់ទំនងអន្តរធនាគារ និងអន្តរប្រតិបត្តិការក្នុងចំណោមសមាជិក CSS ទាំងអស់។ ម្ចាស់ប័ណ្ណ CSS អាចធ្វើប្រតិបត្តិការលើម៉ាស៊ីន ATM របស់ PPCBank ដូចជាការដកសាច់ប្រាក់ ការផ្លាស់ប្តូរលេខសម្ងាត់ បោះពុម្ពរបាយការណ៍សង្ខេប ការផ្ទេរប្រាក់អន្តរធនាគារ និងការត្រួតពិនិត្យសមតុល្យ។ ម៉ាស៊ីន ATM របស់ PPCBank អាចគាំទ្រមុខងារពេញលេញនៃប្រតិបត្តិការ CSS ហើយថែមទាំងអនុញ្ញាតឱ្យអ្នកកាន់កាត CSS អាចធ្វើប្រតិបត្តិការនៅគ្រប់ម៉ាស៊ីន ATM របស់ PPCBank ជាប្រាក់រៀល និង/ឬ ជាប្រាក់ដុល្លារ ជាមួយនឹងការគិតកម្រៃសេវាស្តង់ដារអប្បបរមាប៉ុណ្ណោះ។

## ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ៣. ការវិភាគលើពន្ធ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០ ជាមួយនឹងកាតព្វកិច្ចពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "**មាស**" ពីអគ្គនាយដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២០ និង២០២១។

**៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

ទន្ទឹមនឹងការរីករាលដាលនៃវីរុស (COVID-១៩) មកលើសេដ្ឋកិច្ចពិភពលោក ដែលធ្វើឲ្យមានការធ្លាក់ចុះគួរឲ្យកត់សំគាល់ អាចមានផលប៉ះពាល់ខ្លះដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងឆ្នាំ២០២១ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មានការកើនឡើងនៃចំណូល ដែលមានចំណូលការប្រាក់សុទ្ធសរុប ១៩២.២២០លានរៀល ដែលស្មើនឹងការកើនឡើង ១៤.៧% ធៀបនឹងឆ្នាំ២០២០។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំស្របតាមបទបញ្ញត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់នៃអតិផរណា

នៅក្នុងឆ្នាំ២០២១ អតិផរណាមានកម្រិតទាបក្នុងអត្រា ២,៩% ប្រហាក់ប្រហែលនឹងឆ្នាំ២០២០ (២,៩%) ដែលបានចេញផ្សាយដោយ ធនាគារជាតិ នៃកម្ពុជា។ ដូច្នេះមិនមានផលប៉ះពាល់ណាមួយជាសារវន្តនៃអតិផរណាមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល

ដើម្បីបន្តរក្សាស្ថិរភាពថ្លៃ និងលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុសម្រាប់ត្រីមាសបន្ទាប់ ធនាគារជាតិ នៃកម្ពុជា បានបន្តសម្រេចលើជំហរគោលនយោបាយរូបិយវត្ថុដូចខាងក្រោម៖

១. បន្តរក្សាស្ថេរភាពអត្រាប្តូរប្រាក់តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់

២. រក្សាអត្រាការប្រាក់ដេញថ្លៃនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និង ការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ក្នុងកម្រិតសមស្រប

៣. ផ្តល់សន្ទនីយភាពតាមយន្តការ LPCO ក្នុងបរិមាណដែលជួយដល់តម្រូវការប្រាក់រៀលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

៤. បន្តរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងអត្រា ៧% ទាំងប្រាក់រៀល និងប្រាក់ដុល្លារ និង

៥. បង្កើនការស្វែងយល់ និងសម្រួលការប្រើប្រាស់ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)។

ម៉្យាងទៀតក្នុងគោលបំណងរួមចំណែកអភិវឌ្ឍមូលបត្ររដ្ឋ សំដៅអភិវឌ្ឍហិរញ្ញវត្ថុ ជំរុញការធ្វើពិពិធកម្មការកៀរគរប្រភពទុនក្នុងស្រុក និងពង្រឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ធនាគារជាតិ នៃកម្ពុជា បានចេញសារាចរណែនាំចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលកាន់កាប់មូលបត្ររដ្ឋដូចខាងក្រោម៖

១- ទទួលស្គាល់ការថ្លឹងហានិភ័យ 0% ចំពោះមូលបត្ររដ្ឋដែលចារឹកជារូបិយវត្ថុជាតិ ឬជារូបិយបណ្ណ ក្នុងការគណនាអនុបាតសាធនភាព និង

២-ទទួលស្គាល់ជាទ្រព្យសកម្មសន្ទនីយភាពដែលមានគុណភាពខ្ពស់ចំពោះមូលបត្ររដ្ឋ ដែលចារឹកជារូបិយវត្ថុជាតិ ឬជារូបិយបណ្ណ ក្នុងការគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាព។

**ហត្ថលេខាអភិបាលរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក**

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

បានអាន និងឯកភាព



………………………………

លោក YIM, Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល



……………………………

លោក SIM, Sang Ton

សមាជិក



……………………………

លោក KIM, Sung Chul

សមាជិក



……………………………

លោក PARK, Chong Tae

អភិបាលឯករាជ្យ



……………………………

លោក LEE, Myunsang

អភិបាលឯករាជ្យ

PPCBank

# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ ២០២១
# របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក
# របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី១. ភាគហ៊ុនិក

### ក. រចនាសម្ព័ន្ធភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១)

១- ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | | នីតិបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | | នីតិបុគ្គល | មិនមាន | មិនមាន | មិនមាន |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | | នីតិបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | | នីតិបុគ្គល | ១ | ១០.២០០ | ១០% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | | នីតិបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | មិនមាន | មិនមាន | មិនមាន |
| | | នីតិបុគ្គល | ២ | ៩១.៨០០ | ៩០% |

២-ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | - | - | - |
| បុគ្គលិកជាន់ខ្ពស់ | - | - | - |
| និយោជិត | - | - | - |
| **សរុប** | - | - | - |

## ខ. សិទ្ធរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

១- សិទ្ធរបស់ភាគហ៊ុនិក

ភាគហ៊ុនិកទាំងអស់មានសិទ្ធិពេញលេញក្នុងការសម្រេចចិត្តនៅឯកិច្ចប្រជុំ ដោយមិនគិតពីស្ថានភាព និងចំនួនភាគហ៊ុនរបស់ពួកគេឡើយ។ ការសម្រេចចិត្តដែលត្រូវបានអនុម័តនៅកិច្ចប្រជុំភាគហ៊ុនិកអាចត្រូវបានធ្វើឡើងដោយគ្មានការប្រជុំ ប្រសិនបើភាគហ៊ុនិកទាំងអស់យល់ព្រមជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការសម្រេចចិត្តបែបនេះ។

២- ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

ភាគហ៊ុនិកជ្រើសរើស និងតែងតាំងក្រុមប្រឹក្សាភិបាល។ ភាគហ៊ុនិកត្រូវបានការពារដោយក្រុមប្រឹក្សាភិបាល។

៣- ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្ត

ភាគហ៊ុនិកមានសិទ្ធិស្មើ នឹងចំនួនភាគហ៊ុនរបស់ពួកគេក្នុងការបោះឆ្នោតដោយគ្មានការហាមឃាត់។

## គ. មហាសន្និបាតភាគហ៊ុនិក

១- នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

មហាសន្និបាតភាគហ៊ុនិក ត្រូវបានធ្វើឡើងយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ។ សេចក្តីជូនដំណឹងអំពីការប្រជុំត្រូវផ្តល់ជូនជាលាយលក្ខណ៍អក្សរយ៉ាងតិចម្ភៃ(២០)ថ្ងៃជូនដល់សមាជិកទាំងអស់ដើម្បីចូលរួមប្រជុំ។ សេចក្តីជូនដំណឹងត្រូវបញ្ជាក់ពី កាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈនៃការប្រជុំ។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការប្រជុំមហាសន្និបាត ហើយការប្រជុំវិសាមញ្ញអាចនឹងត្រូវកោះប្រជុំគ្រប់ពេល។

២- ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុម នៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
